ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ ៣៧២៨/២៥ អគរ

ថ្ងៃ សុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០២៥

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការបំពេញបែបបទគយ ចំពោះទំនិញមានដើមកំណើតនៅសហរដ្ឋអាមេរិក និងនាំចូលពីសហរដ្ឋអាមេរិក

អនុលោមតាមបញ្ញត្តិប្រកាសលេខ ៦៣២ សហវ.ប្រក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអត្រាពន្ធគយលើទំនិញនាំចូលពីសហរដ្ឋអាមេរិក និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សូមណែនាំនូវនីតិវិធីនៃការបំពេញបែបបទគយ ចំពោះទំនិញមានដើមកំណើតនៅសហរដ្ឋអាមេរិក និងនាំចូលពីសហរដ្ឋអាមេរិក ដូចខាងក្រោម៖

**ក. និយមន័យ**

**១. ទំនិញប្រើរួច** សំដៅដល់ទំនិញដែលបានឆ្លងកាត់ការប្រើប្រាស់រួច ឬបានកាន់កាប់រួចដោយអ្នកប្រើប្រាស់ដែលមិនមែនជាអ្នកផលិត, អ្នកចែកចាយ, ឬអ្នកលក់បន្ត។

**២. យានយន្តដែលអាចស្នើសុំអត្រាពន្ធគយ 0%៖**

**២.១. រថយន្តត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖**

- ផលិតនៅ សហរដ្ឋអាមេរិក
- ជារថយន្តដែលមានឆ្នាំម៉ូដែល ១ឆ្នាំមុនឆ្នាំបច្ចុប្បន្ន (N-1) ឬក្នុងឆ្នាំបច្ចុប្បន្ន (N) ឬ ១ឆ្នាំក្រោយឆ្នាំបច្ចុប្បន្ន (N+1) និងមានចម្ងាយប្រើប្រាស់មិនលើសពី ៥ 000 គីឡូម៉ែត្រ ក្នុងកញ្ចក់ម៉ែត្ររថយន្ត (Odometer) និង
- ជារថយន្តដែលមានស្ថានភាពល្អក្នុងទម្រង់ដើម ដែលមិនបុក ប៉ះទង្គិច ខូចខាត រងការលិចទឹក ឬរងគ្រោះថ្នាក់ផ្សេងទៀត។

**២.២. ទោចក្រយានយន្ត ត្រីចក្រយានយន្ត និង ATV ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖**

- ផលិតនៅ សហរដ្ឋអាមេរិក
- ជាយានយន្តដែលមានឆ្នាំម៉ូដែល ១ឆ្នាំមុនឆ្នាំបច្ចុប្បន្ន (N-1) ឬក្នុងឆ្នាំបច្ចុប្បន្ន (N) ឬ ១ឆ្នាំក្រោយឆ្នាំបច្ចុប្បន្ន (N+1) និងមានចម្ងាយប្រើប្រាស់មិនលើសពី ២ 000 គីឡូម៉ែត្រ ក្នុងកញ្ចក់ម៉ែត្រយានយន្ត (Odometer) និង
- ជាយានយន្តដែលមានស្ថានភាពល្អក្នុងទម្រង់ដើម ដែលមិនបុក ប៉ះទង្គិច ខូចខាត រងការលិចទឹក ឬរងគ្រោះថ្នាក់ផ្សេងទៀត។

**៣. ការដឹកជញ្ជូនត្រង់** សំដៅដល់ការដឹកជញ្ជូនទំនិញពីសហរដ្ឋអាមេរិកមកកាន់ព្រះរាជាណាចក្រកម្ពុជា ដោយមិនឆ្លងកាត់ប្រទេសដទៃ លើកលែងតែករណីការផ្ទេរមធ្យោបាយដឹកជញ្ជូន (Transshipment) ឬការឆ្លងកាត់គយ (Customs Transit)។

## ខ. លក្ខខណ្ឌ និងនីតិវិធីនៃការបំពេញបែបបទគយ

**១.** ការនាំចូលនូវមុខទំនិញហាមឃាត់ ឬទំនិញជាប់កម្រិតកំណត់ ត្រូវអនុវត្តតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ៣៧០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យអនុវត្តបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**២.** ដើម្បីទទួលបានអត្រាពន្ធគយអនុគ្រោះ 0% អ្នកនាំចូល ឬតំណាង ត្រូវ៖

- ប្រកាសប្រតិវេទន៍ដើមកំណើតទំនិញ (Declaration of Origin – DO) តាមទម្រង់ DO Form US ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។ ការប្រកាសនេះត្រូវធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកតាមរយៈប្រព័ន្ធ CVDS (https://value.customs.gov.kh/CV)
- ធានាថាទំនិញដែលប្រកាសនៅលើ DO នោះ ពិតជាត្រូវបានផលិត និងមានដើមកំណើតនៅសហរដ្ឋអាម៉េរិកប្រាកដមែន
- បង្ហាញឯកសារគាំទ្រ ឬលក្ខណៈសម្គាល់ដែលបញ្ជាក់ថាទំនិញនោះត្រូវបានផលិតនៅសហរដ្ឋអាម៉េរិកក្នុងករណីមានការតម្រូវពីមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច។

**៣.** នីតិវិធីនៃការផ្ទៀងផ្ទាត់ និងឯកភាពលើប្រតិវេទន៍ដើមកំណើតទំនិញនេះ ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីនៃការផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញក្រោមក្របខណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ជាធរមាន។

**៤.** ព័ត៌មានត្រូវបំពេញបន្ថែមក្នុងប្រតិវេទន៍គយក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាសុីគូដា)៖

- ប្រតិវេទករ ត្រូវបំពេញកូដ KHUSPT (KH and US Preferential Tariff) ក្នុងប្រអប់លេខ ៣៦ (ពន្ធអនុគ្រោះ) នៃប្រតិវេទន៍គយ។
- ប្រតិវេទករ ត្រូវបំពេញលេខនិងកាលបរិច្ឆេទនៃ DO ដែលទទួលបានការឯកភាពពី អគរ នៅក្នុងផ្នែកឯកសារយោង (Attachment Document Page) ដោយប្រើប្រាស់កូដប្រភេទឯកសារ 862 (Declaration of Origin) នៅពេលចុះបញ្ជិកាប្រតិវេទន៍គយ។
- មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច និងប្រតិវេទករ អាចផ្ទៀងផ្ទាត់ឯកសារពាក់ព័ន្ធ តាមរយៈការប្រើប្រាស់មុខងារ View Attached Documents នៃប្រតិវេទន៍គយ ក្នុងប្រព័ន្ធអាសុីគូដា។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពគយនិងរដ្ឋាករ ប្រតិវេទករ ព្រមទាំងធុរជនពាក់ព័ន្ធទាំងអស់ ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីគោរពជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមភស្តុភារកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

លិខិតលេខ៣៧២៤/២៥អគរ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
General Department of Customs and Excise of Cambodia

**លេខប្រតិវេទន៍ដើមកំណើតទំនិញ:** *[auto generate] DOUS-00001*
**DO Number**

**ប្រតិវេទន៍ដើមកំណើតទំនិញ**
**សម្រាប់ទំនិញមានដើមកំណើតពីសហរដ្ឋអាមេរិក**
**ឧម្រង់ DO Form US**
**Declaration of Origin for US Originating Goods**
**DO Form US**

1. អ្នកនាំចូល Importer
លេខ អតប VAT No.
អាសយដ្ឋាន Address

2. អ្នកនាំចេញ Exporter
អាសយដ្ឋាន Address

3. អ្នកផលិត Producer (Optional)
អាសយដ្ឋាន Address

4. មធ្យោបាយដឹកជញ្ជូន Means of transport and route
*[by sea/by air/by land]*
លេខនិងកាលបរិច្ឆេទឯកសារដឹកជញ្ជូន Number and date of transport document

5. លេខ និងកាលបរិច្ឆេទវិក្កយបត្រ
Number and date of invoices

| 6. លរ. No. | 7. ការបរិយាយទំនិញ Description of goods | 8. ទម្ងន់ដុល ឬបរិមាណផ្សេងទៀត Gross weight or other quantity | 9. ព័ត៌មានបន្ថែម (សម្រាប់តែមុខទំនិញយានយន្ត) Additional information (For motor vehicles only) *[Model year, mileage, and vehicle condition]* |
|---|---|---|---|
| 1. | | | |
| 2. | | | |
| 3. | | | |
| 4. | | | |
| 5. | | | |
| 6. | | | |

10. សម្គាល់ Remarks

11. ខ្ញុំសូមធានាអះអាងថា ព័ត៌មានខាងលើគឺត្រឹមត្រូវនិងពិតប្រាកដ និងសូមធានាថា ទំនិញដែលប្រកាសខាងលើពិតជាបានផលិត និងមានដើមកំណើតនៅសហរដ្ឋអាមេរិកប្រាកដមែន។ ក្នុងករណីរកឃើញថា ការប្រកាសនេះខុសពីការពិត ខ្ញុំសូមទទួលទោសទណ្ឌតាមក្រមព្រហ្មទណ្ឌ និងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។
I certify that the information on this document is true and accurate and the goods above is made and originated in the United States of America. In case any false statement is made, I accept that I am liable under Criminal Code and other relevant laws and regulations.

បញ្ជាក់ដោយក្រុមហ៊ុននាំចូល Certification by Importer
*[System-generated QR Code]*
*[Name of Importer/Declarant]*

កាលបរិច្ឆេទ Date

## **កំណត់សម្គាល់**

## **Overleaf Notes**

1. **លេខប្រតិវេទន៍ដើមកំណើតទំនិញ** ៖ លេខរៀងសម្គាល់ឯកសារនឹងត្រូវបានផ្ដល់ឱ្យដោយស្វ័យប្រវត្តិពីប្រព័ន្ធ។
   **DO Number**: Reference number of Declaration of Origin which is system-generated.

2. **អ្នកនាំចូល និងអ្នកនាំចេញ** ៖ ត្រូវបំពេញព័ត៌មានលម្អិតរបស់អ្នកនាំចូល (រួមមាន ឈ្មោះ លេខ អតប អាសយដ្ឋាន និងប្រទេស) ក្នុងប្រអប់ទី ១ និង របស់អ្នកនាំចេញ (រួមមាន ឈ្មោះ អាសយដ្ឋាន និងប្រទេស) ក្នុងប្រអប់ទី ២។
   **IMPORTER AND EXPORTER:** Provide the details of the importer ( including name, VAT No., address, and country ) in Box 1, and exporter of the goods ( including name, address and country ) in Box 2.

3. **អ្នកផលិត** ៖ បំពេញព័ត៌មានរបស់អ្នកផលិតទំនិញ (រួមមាន ឈ្មោះ អាសយដ្ឋាន និងប្រទេស) ក្នុងប្រអប់ទី ៣ ប្រសិនបើដឹង។
   **PRODUCER:** Provide the details of the producer of the goods ( including name, address and country ) in Box 3, if known.

4. **មធ្យោបាយដឹកជញ្ជូន** ៖ ត្រូវបំពេញលេខនិងកាលបរិច្ឆេទរបស់ Bill of Lading សម្រាប់ផ្លូវទឹក, Airway Bill សម្រាប់ផ្លូវអាកាស និង Truck Bill of Lading សម្រាប់ផ្លូវគោក ក្នុងប្រអប់លេខ ៤។
   **MEANS OF TRANSPORT AND ROUTE:** Enter the transport document number and date in Box 4 ( Bill of Lading for maritime shipments, Airway Bill for air shipments, or Truck Bill of Lading for land shipments ).

5. **ការបរិយាយទំនិញ** ៖ ត្រូវបំពេញការបរិយាយទំនិញឱ្យបានពេញលេញគ្រប់គ្រាន់ ដើម្បីអាចកំណត់អត្តសញ្ញាណទំនិញបានក្នុងប្រអប់លេខ ៧។ គួរបំពេញព័ត៌មានសមស្របតាមប្រភេទទំនិញដែលបញ្ជាក់ពីអត្តសញ្ញាណទំនិញជាក់លាក់ ដូចជា ម៉ាក ម៉ូដែល លេខតួ លេខម៉ាស៊ីន ជាដើម។ សម្រាប់មុខទំនិញយានយន្ត ត្រូវបំពេញព័ត៌មានបន្ថែមផ្សេងទៀត ក្នុងប្រអប់លេខ ៩។
   **DESCRIPTION OF GOODS:** Enter the description of each good so that it is sufficiently detailed, allowing the product to be identified in Box 7. Relevant information should be provided according to the type of goods, specifying the exact identification details such as brand, model, chassis number, engine number, etc. For motor vehicles, additional information must be filled in Box 9.

6. **ព័ត៌មានបន្ថែម (សម្រាប់តែមុខទំនិញយានយន្ត)** ៖ ក្នុងករណីទំនិញក្នុងប្រអប់លេខ ៧ ជាប្រភេទយានយន្ត ត្រូវបំពេញព័ត៌មានបន្ថែមក្នុងប្រអប់លេខ ៩ ដែលរួមមានដូចជា ឆ្នាំម៉ូដែល រយៈចំងាយប្រើប្រាស់ និងស្ថានភាពយានយន្ត។ ឧទាហរណ៍៖ ឆ្នាំម៉ូដែល ២០២X, រយៈចម្ងាយប្រើប្រាស់ xx KM, ស្ថានភាពល្អក្នុងទម្រង់ដើម។
   **ADDITONAL INFORMATION ( FOR MOTOR VEHICLES ONLY ):** When the goods listed in Box 7 are motor vehicles, additional details must be provided in Box 9, including the model year, mileage, and vehicle condition. For example: Model year 202X, mileage xx KM, good original condition.